ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះសីហនុ**
សំណុំរឿងព្រហ្មទណ្ឌលេខ៧០៦ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២០
សំណុំរឿងជំនុំជម្រះលេខ៧៩៨ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០
កាលបរិច្ឆេទសវនាការថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០
កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី១២ ខែមករា ឆ្នាំ២០២១
សាលក្រមលេខ: ២៥/០៥ “ឈ”
ចុះថ្ងៃអង្គារ ១៤រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០២១

[redacted]

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះសីហនុ

**បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តព្រះសីហនុ**
**ដោយមានសមាសភាពដូចតទៅ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**ចៅក្រមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

[redacted]

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៧០៦ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលមានជាប់ចោទដូចខាងក្រោម:

១.ឈ្មោះ [redacted] **សុភី ហៅ ញ៉ាញ់** ភេទប្រុស អាយុ៣០ឆ្នាំ កើតឆ្នាំ១៩៩០ ជនជាតិខ្មែរ មុខរបរកម្មករសំណង់ កម្រិតវប្បធម៌ ថ្នាក់ទី១១ មានទីកន្លែងកំណើតនៅ [redacted] ខេត្តព្រះសីហនុ មានទីលំនៅមុនពេលឃុំខ្លួននៅបន្ទប់ជួល ក្រុមទី៣៨ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] ឪពុកឈ្មោះ [redacted] ផល “រ” ម្តាយឈ្មោះ [redacted] ប៊ុណ្ណា “រ” ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ “ធ្លាប់ជាប់ពន្ធនាគាររយៈពេល ០១ឆ្នាំ ពាក់ព័ន្ធករណីអំពើលួច”។ (**ក្នុងឃុំ**)

ជាប់ចោទពីបទ **ជួញដូរ សម្រួលឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុមទី៣៨ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ មាត្រា៤៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ឈ្មោះ [redacted] **សុជាតិ** ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ ជាងសំណង់ កម្រិតវប្បធម៌ ថ្នាក់ទី៥ មានទីកន្លែងកំណើត [redacted] ខេត្តព្រះសីហនុ មានទីលំនៅមុនពេលឃុំខ្លួននៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] ចាន់ថន មានកូនចំនួន ០២នាក់ ឪពុកឈ្មោះ [redacted] សុខុម “រ” ម្តាយឈ្មោះ [redacted] សារុំ “ស” ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ “គ្មាន”។ (**ក្នុងឃុំ**)

ជាប់ចោទពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុមទី៣៨ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.ឈ្មោះ [redacted] **ម៉ារី ហៅ តី** ភេទស្រី អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ កម្រិតវប្បធម៌ ថ្នាក់ទី៥ មានទីកន្លែងកំណើតនៅ [redacted] ខេត្តព្រៃវែង មានទីលំនៅមុនពេលឃុំខ្លួននៅបន្ទប់ជួល ក្រុមទី៣៨ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្តីឈ្មោះ [redacted] សុភី ឪពុកឈ្មោះ [redacted] បញ្ញា "ស" ម្តាយឈ្មោះ [redacted] ឡូច "ស" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន"។ **(ក្នុងឃុំ)**

ជាប់ចោទពីបទ **សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, សម្រួលឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុមទី៣៨ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ, មាត្រា៤០ ,មាត្រា៤៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤.ឈ្មោះ [redacted] **ញ៉ាង ហៅ ញ៉ា** ភេទប្រុស អាយុ ១៦ឆ្នាំ កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៣ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ កម្រិតវប្បធម៌ថ្នាក់ទី៦ មានទីកន្លែងកំណើតនៅ [redacted] ខេត្តព្រះសីហនុ មានទីលំនៅមុនពេលឃុំខ្លួននៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នៅលីវ ឪពុកឈ្មោះ [redacted] ហុង "រ" ម្តាយឈ្មោះ [redacted] ផាត "រ" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន"។ **(ក្នុងឃុំ)**

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុមទី៣៨ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ញ៉ាង ហៅ ញ៉ា។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៥៥៣៥ អ.យ.ច/២០ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ របស់ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

បានឃើញ ដីកាដំណោះស្រាយលេខ ៣៧៩១ ត.៣/១៩ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ។

បានឃើញ ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ ៥៦០៦ ត.ព.វ/១៩ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ។

**អង្គហេតុដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យមានដូចតទៅ ÷**

កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៦ និង ៣៦នាទី ស្ថិតនៅចំនុចក្រុមទី៣៨ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កម្លាំងការិយាល័យគ្រឿងញៀន បានបង្ក្រាបករណី **ជួញដូរ ផ្តល់ទីតាំង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** មួយករណី ដោយកម្លាំងជំនាញបានឱ្យប្រាក់ទៅភ្នាក់ងារសម្ងាត់ដើម្បីទំនាក់ទំនងទិញថ្នាំញៀនពីឈ្មោះ [redacted] **សុភី** ហៅ **ញ៉ាញ់**។ ពេលទិញបានហើយកម្លាំងភ្នាក់ងារសម្ងាត់បានឱ្យប្រាក់ទៅឈ្មោះ [redacted] **សុជាតិ** ជាអ្នកទទួលប្រាក់ ព្រមទាំងទទួលប្រាក់ចំនួន៨០.០០០រៀល មកវិញ រួចត្រូវកម្លាំងសមត្ថកិច្ចសម្រុកចូលបន្ទប់ឈ្មោះ [redacted] **សុភី** ហៅ **ញ៉ាញ់** និងធ្វើការឃាត់ខ្លួនឈ្មោះ [redacted] **សុភី** ហៅ **ញ៉ាញ់**, ឈ្មោះ [redacted] **សុជាតិ** និងឈ្មោះ [redacted] **ម៉ារី** និងធ្វើការឆែកឆេរឃើញមានម្សៅសចំនួន ០៤កញ្ចប់ នៅក្នុងហោប៉ៅខោ របស់ឈ្មោះ [redacted] **សុភី** ហៅ **ញ៉ាញ់** ព្រមទាំងដកហូតដបជក់ចំនួន ០២, ទូរស័ព្ទចំនួន ០២គ្រឿង និងប្រាក់ចំនួន ១០០.០០០រៀល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **សុភី** បានឆ្លើយថា ៖ នៅថ្ងៃកើតហេតុ សមត្ថកិច្ចបានឃាត់ខ្លួនករណីគ្រឿងញៀន ដោយឈ្មោះ [redacted] **ញ៉ាង** បានឱ្យខ្លួនលក់ថ្នាំញៀនឱ្យទៅឈ្មោះ **វុន** ក្នុងតម្លៃ ៣០ដុល្លារ។ ខ្លួនមិនធ្លាប់បានយកថ្នាំញៀនពីឈ្មោះ [redacted] **សុជាតិ** ឱ្យទៅឈ្មោះ **វុន** ឡើយ។ នៅពេលខ្លួនលក់ថ្នាំញៀនឱ្យឈ្មោះ **វុន** នោះ ឈ្មោះ [redacted] **សុជាតិ** កំពុងស្ថិតនៅក្នុងផ្ទះ និងបានឱ្យគេយកលុយទៅអាប់ឱ្យទៅអ្នកទិញថ្នាំញៀនឈ្មោះ **វុន** ដោយមិនបានឱ្យគេយកថ្នាំញៀនទៅលក់ឱ្យឈ្មោះ **វុន** ឡើយ។ ចំពោះឈ្មោះ [redacted] **ម៉ារី** មិនជាប់ពាក់ព័ន្ធករណីនេះឡើយ ហើយក៏មិនធ្លាប់បានឱ្យគេយកថ្នាំញៀនទៅហុចឱ្យអ្នកដែលទិញគ្រឿងញៀនដែរ។ ចំពោះថ្នាំញៀនដែលខ្លួនយកមកលក់ឱ្យគេនោះ គឺឈ្មោះ [redacted] **ញ៉ាង** ហៅ **ញ៉ា** បានទិញយកមកទុកនៅនឹងខ្លួន ទើបខ្លួនបានយកគ្រឿងញៀននោះទៅលក់។ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចបានដកហូតមានចំនួន ០៤កញ្ចប់ ជាប្រភេទម៉ាទឹកកក។ ចំពោះឈ្មោះ [redacted] **សុជាតិ** គេជាអ្នកមកលេងបន្ទប់របស់ខ្លួន និងជាអ្នកដូរលុយ។ ខ្លួនស្គាល់ឈ្មោះ [redacted] **ញ៉ាង** រយៈពេល ០១ឆ្នាំមកហើយ និងបានទំនាក់ទំនងគេលក់គ្រឿងញៀនរយៈពេលប្រហែល ០១ខែប៉ុណ្ណោះ។ នៅពេលលក់នោះ ខ្លួនមិនបានឱ្យលុយទៅឈ្មោះ [redacted] **ញ៉ាង** ហៅ **ញ៉ា** ឡើយ។ នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនគេមិនបានដកហូតថ្នាំញៀនពីប្រពន្ធខ្លួនឈ្មោះ [redacted] **ម៉ារី** នោះទេ។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនរយៈពេលប្រហែល ០៤ ទៅ ០៥ឆ្នាំមកហើយដោយប្រើប្រាស់ ០១ខែម្តង។ ខ្លួនតែងតែប្រើប្រាស់គ្រឿងញៀនជាមួយប្រពន្ធឈ្មោះ [redacted] **ម៉ារី** ឈ្មោះ [redacted] **ញ៉ាង** និងឈ្មោះ [redacted] **សុជាតិ** ដោយពេលប្រើប្រាស់នោះ គឺប្រើប្រាស់នៅក្នុងបន្ទប់ជួលរបស់ខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] **ញ៉ាង** បានឆ្លើយថា ៖ នៅថ្ងៃកើតហេតុសមត្ថកិច្ចបានឃាត់ខ្លួននៅម្តុំអូរ១ ដោយបានដកហូតពីខ្លួននូវថ្នាំញៀនចំនួន ០៣កញ្ចប់ ជារបស់ឈ្មោះ [redacted] **សុភី** ហៅ **ញ៉ាញ់**។ ខ្លួនស្គាល់ឈ្មោះ [redacted] **សុភី** ហៅ **ញ៉ាញ់** តាមរយៈបងរបស់ខ្លួន។ កន្លងមកឈ្មោះ [redacted] **សុភី** ធ្លាប់បានប្រើខ្លួនឱ្យយកថ្នាំញៀនទៅឱ្យគេក្នុងតម្លៃ ១០០ដុល្លារ ដោយខ្លួនក៏ធ្លាប់បានទិញគ្រឿងញៀនឱ្យឈ្មោះ [redacted] **សុភី** ដែរ ហើយខ្លួនក៏ធ្លាប់ទិញគ្រឿងញៀនយកមកទុកនៅឈ្មោះ [redacted] **សុភី** ហើយក៏ត្រូវបានគេយកទៅលក់ផងដែរ។ ខ្លួនបានប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ [redacted] **សុភី** ចំនួន ០៤ ទៅ ០៥ដង ដោយនៅលើកចុងក្រោយខ្លួនជាអ្នកទិញគ្រឿងញៀន យកមកប្រើប្រាស់នៅបន្ទប់ជួលរបស់គេ ហើយខ្លួនមិនធ្លាប់ជួយលក់គ្រឿងញៀនឱ្យឈ្មោះ [redacted] **សុភី** នោះឡើយ។

-ជនជាប់ចោទឈ្មោះ [redacted] **ម៉ារី** បានឆ្លើយថា ៖ សមត្ថកិច្ចបានឃាត់ខ្លួននៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ នៅម្តុំអូរ១ នៅចំណុចបន្ទប់ជួលរបស់ឈ្មោះ [redacted] **សុភី**។ នៅពេលឃាត់ខ្លួននៅបន្ទប់នោះ មានខ្លួន, ឈ្មោះ [redacted] **សុភី** និងឈ្មោះ [redacted] **សុជាតិ** ដោយដកហូតបានថ្នាំញៀនចំនួន ០៩កញ្ចប់ (ប្រភេទម៉ាទឹកកក)។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនរយៈពេលប្រហែល កន្លះឆ្នាំមកហើយ។ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចបានដកហូតស្ថិតនៅលើខ្លួនឈ្មោះ [redacted] **សុភី** ដោយខ្លួនមិនបានដឹងថា ប្តីរបស់ខ្លួនឈ្មោះ [redacted] **សុភី** បានថ្នាំញៀនទាំងនោះមកពីណាឡើយ។ ចំពោះឈ្មោះ [redacted] **សុភី** មិនធ្លាប់បានឱ្យខ្លួនយកគ្រឿងញៀនទៅលក់ឱ្យគេឡើយ ហើយខ្លួនក៏ធ្លាប់ដឹងថា ប្តីខ្លួនឈ្មោះ [redacted] **សុភី** ជាអ្នកជួញដូរគ្រឿងញៀនដែរ។ ចំពោះបន្ទប់ជួលនោះ ប្តីខ្លួន និងខ្លួន ជាអ្នកជួលដើម្បីរស់នៅជុំគ្នា ហើយនៅពេលប្រើប្រាស់គ្រឿងញៀនក៏ប្រើប្រាស់នៅក្នុងបន្ទប់ជួលនោះដែរ។ នៅថ្ងៃកើតហេតុឈ្មោះ **ជាតិ** បានឱ្យប្តីខ្លួនឈ្មោះ [redacted] **សុភី** ហុចគ្រឿងញៀនឱ្យគេ ប៉ុន្តែខ្លួនមិនបានដឹងថា គេបានយកថ្នាំញៀនទាំងនោះចេញពីកន្លែងណាឡើយ ហើយថ្នាំញៀននោះជារបស់អ្នកណាក៏ខ្លួនមិនបានដឹងដែរ។

-ជនជាប់ចោទឈ្មោះ [redacted] **សុជាតិ** បានឆ្លើយថា ៖ នៅថ្ងៃកើតហេតុ ខ្លួនរៀបចំប្រើប្រាស់ថ្នាំញៀននៅក្នុងបន្ទប់របស់ឈ្មោះ [redacted] **សុភី** ក៏បានឃើញឈ្មោះ [redacted] **សុភី** ដើរចេញនៅខាងក្រៅបន្ទប់ បន្ទាប់មកគេបានឱ្យខ្លួនដូរលុយចំនួន ៥០ដុល្លារ ហើយក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនមិនធ្លាប់បានជួយលក់គ្រឿងញៀនឱ្យគេឡើយ។ ចំពោះលុយដែល ៥០ដុល្លារនោះ ឈ្មោះ [redacted] **សុភី** យកមកប្តូរជាមួយខ្លួនតែប៉ុណ្ណោះ។ ខ្លួនទទួលស្គាល់ចម្លើយដែលខ្លួនបានឆ្លើយកន្លងមកដោយមិនមានការកែប្រែឡើយ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងភស្តុតាងនានាដែលមានក្នុងសំណុំរឿងខាងលើឃើញថា ជនជាប់ចោទឈ្មោះ [redacted] **សុភី**, [redacted] **ញ៉ាង**, [redacted] **ម៉ារី** និងឈ្មោះ [redacted] **សុជាតិ** ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន។ ហេតុនេះតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ល្មើសជនជាប់ចោទខាងលើតាមដីកាសន្និដ្ឋានស្ថាពរលេខ ៥៥៣៥ អ.យ.ច/២០ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល ស្នើសុំដល់ចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទខាងលើតាមច្បាប់។



Scanned with CamScanner

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ៖ ក្រោយពីបានស្តាប់ចម្លើយរបស់កូនក្តីខ្លួន និងភស្តុតាងនានាដែលមានក្នុងសំណុំរឿងឃើញថា កូនក្តីខ្លួនបានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលហើយ គាត់ក៏មានការសោកស្តាយនូវកំហុសរបស់ខ្លួន លើសពីនេះទៅទៀតកូនក្តីខ្លួនជាអនីតិជន ដែលពុំបានធ្វើការគិតពិចារណា ឱ្យបានល្អិតល្អន់ទើបឈានដល់ការជួញដូរគ្រឿងញៀនបែបនេះ។ ហេតុដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំដល់ក្រុមប្រឹក្សាជំនុំជម្រះមេត្តាផ្តល់ស្តានសម្រាលដល់កូនក្តីខ្លួនផង។

-សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] សុភី ហៅ ញ៉ាញ់ ៖ ស្នើសុំដល់តុលាការបន្ធូរបន្ថយទោស។

-សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] ញ៉ាង ហៅ ញ៉ា ៖ ស្នើសុំដល់តុលាការបន្ធូរបន្ថយទោស។

-សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ារី ៖ ស្នើសុំដល់តុលាការបន្ធូរបន្ថយទោស។

-សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ ៖ ស្នើសុំដល់តុលាការបន្ធូរបន្ថយទោស។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានកត់សំគាល់របស់តំណាងអយ្យការប្តឹងសុំ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានកត់សំគាល់របស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តព្រះសីហនុ
## យល់ឃើញថា

១.ជនជាប់ចោទឈ្មោះ [redacted] **សុភី** បានឆ្លើយថា ៖ នៅថ្ងៃកើតហេតុឈ្មោះ [redacted] **ញ៉ាង** បានឱ្យខ្លួនលក់ថ្នាំញៀនឱ្យទៅឈ្មោះ **វ៉ុន** ក្នុងតម្លៃ ៣០ដុល្លារ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ នៅពេលខ្លួនលក់ថ្នាំញៀនឱ្យឈ្មោះ **វ៉ុន** នោះឈ្មោះ [redacted] **សុជាតិ** កំពុងស្ថិតនៅក្នុងផ្ទះ និងបានឱ្យគេយកលុយទៅអាប់ឱ្យទៅអ្នកទិញថ្នាំញៀនឈ្មោះ **វ៉ុន** ដោយមិនបានឱ្យគេយកថ្នាំញៀនទៅលក់ឱ្យឈ្មោះ **វ៉ុន** ឡើយ។ ថ្នាំញៀនដែលខ្លួនយកមកលក់ឱ្យគេ ឈ្មោះ [redacted] **ញ៉ាង** ហៅ **ញ៉ា** បានទិញយកមកទុកនៅនឹងខ្លួន ទើបខ្លួនបានយកគ្រឿងញៀននោះទៅលក់។ ដែលចម្លើយរបស់ជនជាប់ចោទខាងលើ មានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ម៉ារី** ដែលបានឆ្លើយថា ខ្លួនធ្លាប់ដឹងថា ប្តីខ្លួនឈ្មោះ [redacted] **សុភី** ជាអ្នកជួញដូរគ្រឿងញៀន ហើយនៅថ្ងៃកើតហេតុឈ្មោះ **ជាតិ** បានឱ្យប្តីខ្លួនឈ្មោះ [redacted] **សុភី** ហុចគ្រឿងញៀនឱ្យគេ ប៉ុន្តែខ្លួនមិនបានដឹងថា គេបានយកថ្នាំញៀនទាំងនោះចេញពីកន្លែងណាឡើយ ហើយថ្នាំញៀននោះជារបស់អ្នកណាក៏ខ្លួនមិនបានដឹងដែរ។ លើសពីនេះទៅទៀតជនជាប់ចោទឈ្មោះ [redacted] **ញ៉ាង** ក៏បានទទួលស្គាល់ថា ឈ្មោះ [redacted] **សុភី** ធ្លាប់ប្រើខ្លួនឱ្យលក់ថ្នាំញៀនឱ្យគេ ក្នុងតម្លៃ ១០០ដុល្លារផងដែរ។

២.ជនជាប់ចោទឈ្មោះ [redacted] **សុជាតិ** បានឆ្លើយថា ៖ នៅថ្ងៃកើតហេតុ ខ្លួនរៀបចំប្រើប្រាស់ថ្នាំញៀននៅក្នុងបន្ទប់របស់ឈ្មោះ [redacted] **សុភី** ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនមិនធ្លាប់បានជួយលក់គ្រឿងញៀនឱ្យគេឡើយ។ ចំពោះលុយដែល៥០ដុល្លារនោះ ឈ្មោះ [redacted] **សុភី** យកមកប្តូរជាមួយខ្លួនតែប៉ុណ្ណោះ។ ដែលចម្លើយរបស់ជនជាប់ចោទខាងលើគ្រាន់តែជាចម្លើយដែលឆ្លើយដើម្បីគេចវេសពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយមិនមានភស្តុតាង និងសាក្សីណាម្នាក់មកបញ្ជាក់ឱ្យតុលាការ ជឿជាក់បានឡើយ ផ្ទុយមកវិញបើតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **ម៉ារី** បានបញ្ជាក់ថា នៅថ្ងៃកើតហេតុឈ្មោះ [redacted] **សុជាតិ** បានឱ្យប្តីខ្លួនឈ្មោះ [redacted] **សុភី** ហុចគ្រឿងញៀនឱ្យគេ ប៉ុន្តែខ្លួនមិនបានដឹងថា គេបានយកថ្នាំញៀនទាំងនោះចេញពីកន្លែងណាឡើយ។

៣.ជនជាប់ចោទឈ្មោះ [redacted] **ម៉ារី** និងឈ្មោះ [redacted] **សុភី** បានឆ្លើយប្រហាក់ប្រហែលគ្នាថា ទីតាំងកន្លែងកើតហេតុគឺជាបន្ទប់ជួលរបស់ពួកគេ ដែលជួលសម្រាប់ស្នាក់នៅជាមួយគ្នា ហើយនៅពេលដែលខ្លួនប្រើប្រាស់គ្រឿងញៀន គឺប្រើប្រាស់នៅក្នុងបន្ទប់ជួលនោះតែម្តង ចំណែកឈ្មោះ [redacted] **សុជាតិ** ក៏បានមកប្រើប្រាស់គ្រឿងញៀននៅក្នុងបន្ទប់ជួលរបស់ខ្លួនដែរ។ ដែលចម្លើយរបស់ជនជាប់ចោទខាងលើមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុជាតិ** ដែលបានឆ្លើយថា ខ្លួនពិតជាបានប្រើប្រាស់គ្រឿងញៀននៅក្នុងបន្ទប់ជួលរបស់ឈ្មោះ [redacted] **ម៉ារី** និងឈ្មោះ [redacted] **សុភី** ប្រាកដមែន។

៤.ជនជាប់ចោទឈ្មោះ [redacted] **សុភី**, ឈ្មោះ [redacted] **ម៉ារី** និងឈ្មោះ [redacted] **សុជាតិ** បានឆ្លើយដូចៗគ្នាថា ៖ មុនពេលសមត្ថកិច្ចឃាត់ខ្លួន ពួកខ្លួនក៏បានប្រើប្រាស់គ្រឿងញៀនផងដែរ។ ដែលចម្លើយរបស់ជនជាប់ចោទខាងលើមានភាពស៊ីសង្វាក់ទៅនឹងកំណត់ហេតុធ្វើតេស្តពិសោធន៍រកសារធាតុញៀនក្នុងខ្លួនលេខ ២០.១០៨/០៦.២០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ របស់កងរាជអាវុធហត្ថព្រះសីហនុ គឺវិជ្ជមាន (ជនជាប់ចោទមានសារធាតុញៀនក្នុងខ្លួន)។

៥.តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ វត្ថុតាង និងចម្លើយរបស់ជនជាប់ចោទ អាចបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] **សុភី** ពិតជាបានធ្វើសកម្មភាពប្រព្រឹត្តអំពើ **ជួញដូរ សម្រួលឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**, ឈ្មោះ [redacted] **សុជាតិ** បានប្រព្រឹត្តអំពើ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**, ឈ្មោះ [redacted] **ម៉ារី** បានប្រព្រឹត្តអំពើ **សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, សម្រួលឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** និងឈ្មោះ [redacted] **យ៉ាង** បានប្រព្រឹត្តអំពើ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុមទី៣៨ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០២០ ប្រាកដមែន។

៦.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សុភី** ហៅ **យ៉ាញ់**, ឈ្មោះ [redacted] **ម៉ារី** ហៅ **តី** ឈ្មោះ [redacted] **សុជាតិ** និងឈ្មោះ [redacted] **យ៉ាង** ហៅ **យ៉ា** ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ហើយជនជាប់ចោទមានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន គប្បីតុលាការពិចារណាពីការផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ។

៧.តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ២៧១១២/២០ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ ២០២០ របស់អគ្គលេខាធិការដ្ឋានមន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់ថា សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅ ឈ្មោះ **មេតំហ្វេតាមីន** ដែលមានកម្រិតភាពសុទ្ធ ៧៨.៨៩ភាគរយ នៃទម្ងន់សរុប វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានក្នុងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។ ហើយផ្អែកតាមកំណត់ហេតុស្តីពីការបិទបើកកញ្ចប់ដែលសង្ស័យជាសារធាតុញៀន ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ឃើញថាសារធាតុញៀនដែលដកហូតពីជនជាប់ចោទមានទម្ងន់សរុបស្មើនឹង ០.៧៩ក្រាម។ ហេតុដូច្នេះបរិមាណសុទ្ធនៃសារធាតុញៀនដែលបានដកហូតពីជនជាប់ចោទគឺ $(\frac{០.៧៩ \times ៧៨.៨៩}{១០០}) = ០.៦២$ក្រាម។

៨.មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted] **សុភី** ហៅ **យ៉ាញ់** ពីបទ៖ **ជួញដូរ សម្រួលឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤, មាត្រា៤៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ឈ្មោះ [redacted] **សុជាតិ** ពីបទ ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ឈ្មោះ [redacted] **ម៉ារី** ពីបទ ៖ **សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, សម្រួលឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ, មាត្រា៤០ កថាខណ្ឌទី៤ ,មាត្រា ៤៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងឈ្មោះ [redacted] **យ៉ាង** ហៅ **យ៉ា** ពីបទ ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅក្រុមទី៣៨ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០។

៩.ជនជាប់ចោទឈ្មោះ [redacted] **យ៉ាង** ហៅ **យ៉ា** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត១៥.១២.២០០៣ (សំបុត្របញ្ជាក់កំណើតលេខ៥៦៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅសង្កាត់លេខ៤) ជាអនីតិជនដែលមានអាយុក្រោម ១៨ឆ្នាំ គិតត្រឹមថ្ងៃប្រព្រឹត្តបទល្មើស។ ហេតុដូច្នេះ តុលាការនឹងពិចារណាពីការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **យ៉ាង** ហៅ **យ៉ា** តាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

១០.វត្ថុតាងរួមមាន ម្សៅសថ្លាដែលជាសារធាតុញៀន មានទម្ងន់ ០.៧៩ក្រាម និងដបជក់ចំនួន ០២ ជាសម្ភារៈប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស និងវត្ថុដែលច្បាប់ហាមឃាត់។ ហេតុដូច្នេះគប្បីតុលាការសម្រេចរឹបអូសតាមមាត្រា ៩៣ និងមាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

## ហេតុដូច្នេះសម្រេច

១.ផ្តន្ទាទោសលើ

១.១.ឈ្មោះ [redacted] សុភី ហៅ ញ៉ាញ់ ភេទប្រុស អាយុ៣០ឆ្នាំ កើតឆ្នាំ១៩៩០ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ)ឆ្នាំ ០៦ (ប្រាំមួយ)ខែ** ពីបទ **ជួញដូរ សម្រួលឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុមទី៣៨ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៤, មាត្រា៤៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១.២ ឈ្មោះ [redacted] **សុជាតិ** ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ)ឆ្នាំ ០៦ (ប្រាំមួយ)ខែ** ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុមទី៣៨ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១.៣ ឈ្មោះ [redacted] **ម៉ារី ហៅ តី** ភេទស្រី អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ)ឆ្នាំ** ពីបទ **សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន, សម្រួលឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុមទី៣៨ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ, មាត្រា៤០ កថាខណ្ឌទី៤ ,មាត្រា៤៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១.៤ ឈ្មោះ [redacted] **ញ៉ាង ហៅ ញ៉ា** ភេទប្រុស អាយុ ១៦ឆ្នាំ កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៣ ជនជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ)ឆ្នាំ ០៦ (ប្រាំមួយ)ខែ** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុមទី៣៨ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.រឹបអូសវត្ថុតាង ម្សៅសជាសារធាតុញៀន មានទម្ងន់ ០.៧៩ក្រាម និងដបជក់ចំនួន ០២ តាមមាត្រា៩៣ និងមាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ១០កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃអង្គារ ១៤រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សុភី** ហៅ **ញ៉ាញ់**, ឈ្មោះ [redacted] **ម៉ារី** ហៅ **តី**, ឈ្មោះ [redacted] **សុជាតិ** និងឈ្មោះ [redacted] **ញ៉ាង** ហៅ **ញ៉ា**។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍នៅក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

**ថ្ងៃអង្គារ ១៤រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤**

**ខេត្តព្រះសីហនុ ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១**

**ក្រឡាបញ្ជី**

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

[redacted]